សា-សា បាសាក់ SA SA BASSAC
#18 2nd Floor, Sothearos Boulevard
PO Box 2181 Phnom Penh 3, Cambodia
+855 (0)17 774 864
www.sasabassac.com

តើអ្វីដែលនាំឲ្យសិល្បកររូបនេះ លួចពីដើមឈើយំទាំងនេះទាំងកូនឈើនិងដើមឈើ ធំៗ រហូតដល់ជាង៥០០ដើមក្នុងមួយដង ហើយច្រើនដង? ដើម្បីចាក់ទឹកភ្នែកពណ៌សស្រស់លើខ្លួនរបស់គាត់ និងចាប់ផ្តើមដើរតាមជួរដើមឈើសម្រាប់ប្រមូលលក់ទាំងនោះ?

ឥណ្ឌូចិនក្រោមការគ្រប់គ្រងរបស់បារាំង បានធ្វើឯកជននីយកម្មដីរបស់ អាណាចក្រខ្មែរកាលពី១៣០មុន គឺក្នុងឆ្នាំ១៨៨៤។ បន្តិចក្រោយមក ពូជកៅស៊ូក៏បាន ចូលមកដល់ ដោយនាំចូលមកពីប្រទេសប្រេស៊ីល។ ហើយបន្តិចក្រោយមកទៀតបារាំង បាននាំចូលនូវសមីការសេដ្ឋកិច្ច ដែលចាប់ផ្តើមធ្វើឲ្យមានការផ្លាស់ប្តូរផ្នែករូបវ័ន្ត ផ្នែកបញ្ញត្តិ និងផ្នែកស្មារតី នៃធម្មជាតិប្រទេសកម្ពុជាឲ្យក្លាយទៅជាដីសម្រាប់ទាញយកប្រយោជន៍។ ការផ្តល់ដីសម្បទានសេដ្ឋកិច្ចដំបូងក្នុងប្រទេសកម្ពុជា ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩២២ សម្រាប់ចំការ កៅស៊ូ ដែលធំជាងគេក្នុងពិភពលោកគិតត្រឹមឆ្នាំ១៩៧៥។ ភាសាខ្មែរសម្រាប់ពាក្យកៅស៊ូត្រូវបានសរសេរជាអក្សររបស់បារាំងតាមបែបជនជាតិដើមអាមេរិចខាងត្បូង caoutchouc សំដៅទៅដល់ "ដើមឈើយំ" គឺថាដំណក់ទឹកភ្នែកដែលជាជ័រកៅស៊ូនោះធ្លាក់ចុះមកបន្ទាប់ពីត្រូវបានចៀរ។ ប្រហែលជា ការយោងដ៏សំខាន់បំផុតសម្រាប់ពាក្យកៅស៊ូនេះ គឺដោយសារតែវាកើតឡើងតាមរយៈការធ្វើប្រពលវប្បកម្មនាពេលបច្ចុប្បន្ននៃគម្រោងផ្តល់សម្បទានក្នុងសម័យអាណានិគមក្នុងព្រៃជនជាតិភាគតិចនៅប៉ែកឥសាន្តនៃប្រទេសកម្ពុជា៖ កំទេចចោល បោសសំអាត។

ក្នុងប្រទេសកម្ពុជា មានក្រុមជនជាតិដើមភាគតិចនៅតំបន់ខ្ពង់រាបច្រើនជាង២០ ក្រុម ដែលមានវប្បធម៌ខុសគ្នា ភាសាខុសគ្នា និងប្រវត្តិសាស្ត្រខុសគ្នា ពីជនជាតិខ្មែររស់នៅតាមវាលទំនាប។ ខេត្តរតនគីរី គឺជាខេត្តមួយនៅតំបន់ខ្ពង់រាបនៅភាគឥសាន្តបំផុតក្នុងប្រទេសកម្ពុជា ហើយមានជាប់ព្រំដែនជាមួយប្រទេសឡាវនិងប្រទេសវៀតណាម។ ក្រោមការគំរាមកំហែងពីអាណានិយមជាច្រើននោះ សហគមន៍ជាច្រើននៅក្នុងតំបន់នេះ អាចជំនះនឹងឥទ្ធិពលនៃការបង្កើតរដ្ឋដែលបានវិវឌ្ឍន៍ក្នុងប្រទេសកម្ពុជាក្នុងអំឡុងពេលជាងមួយសតវត្សមកហើយ។ ក៏ប៉ុន្តែ អំណាចសេដ្ឋកិច្ចនាពេលបច្ចុប្បន្នហាក់បីដូចជាការគំរាមកំហែងដ៏ខ្លាំងបំផុតទៅលើវប្បធម៌ដែលមានអាយុដ៏យូរលង់មកហើយដែលមានការដាំដុះវិលជុំសម្រាប់ចិញ្ចឹមជីវិត ដូចជា ការដាំ ការច្រូតកាត់ប្រមូលផល និងការកកើតឡើងវិញ ហើយដែលក្នុងនោះ ព្រលឹងព្រៃក្នុងស្រុក និងព្រលឹងដូនតា ដើរតួនាទីយ៉ាងសំខាន់។

ដូចក្នុងការសម្តែងពីមុនរបស់លោក ខ្វៃ សំណាង អំពីមនុស្សកាសែត (២០១១) ដែរកម្រងរូបថតនិងវីដេអូបញ្ចាំងក្នុងអេក្រង់ទោលមនុស្សកៅស៊ូ ចងក្រងឯកសារអំពីការតស៊ូ អរូបិយដ៏ជាក់ច្បាស់មួយ ចំពោះកាលៈទេសៈជាក់លាក់មួយនៃ អ្នកដទៃ ។ បន្តជាមួយនឹងការងារមុនរបស់គាត់ គ្មានចំណង (២០១០, ២០១៣) និង ខ្យល់ (២០១១)នោះ, សំណាង រៀបរាប់ម្តងទៀតអំពីចង្វាក់មួយនៃការសម្តែងបង្ហាញនូវភាពខកចិត្ត នៅទីតាំងដែលមានការប្រទាញប្រទង់មួយចំនួន ប៉ុន្តែ ពេលនេះជាការសម្តែងតាមលំដាប់ដូចក្នុងក្តីសុបិនដ៏រំជួលចិត្ត។

ដោយមានការជំរុញចិត្តមួយផ្នែកតាមរយៈការអនុវត្តការកប់ក្នុងបដិមា នៅក្នុងពិធីឈាបនកិច្ចរបស់ជនជាតិទំពួន ក្នុងស្រុកវ៉ឺនសៃ, សំណាង បានឆ្លាក់ឈើដើមកៅស៊ូដោយដៃនូវបដិមាសត្វដែលរស់ក្នុងភាពភ័យខ្លាច និងម៉ាស៊ីនដែលទទួលរងការគំរាមកំហែងដល់អាយុជីវិត៖ រណាម៉ាស៊ីន សត្វគោ ម៉ាស៊ីនកាយដី សត្វដំរី ម៉ាស៊ីនច្រូត សត្វរមាស រ៉ូឡូកិន សត្វតោ ខ្លាឃ្មុំ ម៉ាស៊ីនឈូស សត្វក្រពើ ឡានដឹកទំនិញ ខ្លាស្វា ឡានចាក់ដី ឈ្លូស។ សហគមន៍នេះស្ថិតនៅលើដីក្រហមខេត្តរតនគីរីដ៏ល្បីល្បាញ។ ប្រសិនបើគ្មានព្រៃនៅលើទីបម្រុងទុកតូចមួយនេះ ដីកប់ខ្មោចនេះទេ វានឹងហាក់បីដូចជាប្រភេទនៃទ្រង់ទ្រាយចុងក្រោយមួយដែលមិនអាចប្រាស្រ័យទាក់ទងគ្នាបាន។ នៅពេលដែលម៉ាស៊ីនទាំងឡាយនៅនឹងថ្កល់និងស្ងាត់ស្ងៀម សត្វទាំងឡាយហាក់បីដូចជាទទួលបានអំណាច។ អវយវៈភេទធ្វើពីឈើលាក់បាំងមិនឲ្យឃើញ ត្រូវបានគេឆ្លាក់ក្នុងទ្រង់ទ្រាយជាអាវុធ។ សត្វទាំងនោះត្រូវបានគេឆ្លាក់ដាក់មាត់ឲ្យបើកចំហរ។ ពួកវាឃ្លាន នៅពេលនេះ ហើយនិងនៅជំនាន់ខាងមុខ។ ហើយពួកគេប្រហែលជាកំពុងបញ្ចេញសម្លេងថា ពួកអាចុយម្រាយ។

What has led the artist to steal from the crying trees, infant and elder, up to 500 at a time, multiple times? To pour the fresh white tears over his body and set about walking the rational cash crop lines?

French Indochina privatized the Khmer monarchy's land 130 years ago, in 1884. Soon after, rubber seeds arrived, imported from Brazil. And soon after that, the French imported an economic equation that began the physical, conceptual and spiritual transformation of Cambodia's nature into exploitable land. Cambodia's first land concession was established in 1922 for a rubber plantation, which, until 1975, was the largest in the world.

The Khmer language transliterates the French transliteration of an indigenous South American word for rubber: caoutchouc. Referred to as the 'crying tree', its latex tears drop after the tapping incision. Perhaps the most biting reference for the word rubber is as it applies to today's intensification of the colonial concession project in Cambodia's northeastern indigenous forests: scraping away, erasing.

There are more than 20 different highland indigenous groups in Cambodia who have distinctly different cultures, languages and histories than those of the lowland Khmer peoples. Rattanikiri is Cambodia's most northeastern highland province, and shares borders with Laos and Vietnam. Threatened by multiple colonialisms, many communities in this area have been able to resist the effects of state-formations that have developed over the last century in Cambodia. However, the economic powers of today seem the strongest threat to their time immemorial culture, which follows an elaborate subsistence cycle of planting, transplanting, harvesting, and regeneration, in which local forest spirits and ancestor spirits play a critical role.

Like Khvay Samnang's earlier *Newspaper Man* (2011), his single-channel video and photographic series *Rubber Man* documents an embodied, abstract resistance to a particular circumstance of the other. Continuous with his previous works *Untitled* (2010, 2013) and *Air* (2011), Khvay again narrates a rhythm of poignant performances at numerous contentious sites, however this time in an agitated, dream-like sequence.

Inspired in part by the burial practices in sculpture at Tampoun cemetaries in Veun Sai district, Khvay hand-carved rubber-wood sculptures of threatened animals and life-threatening machines: Chainsaw, Cow, Bear, Excavator, Elephant, Mulcher, Rhinoceros, Steamroller, Lion, Bulldozer, Crocodile, Loading Truck, Tiger-Monkey, Hauling Truck, Deer.

This unlikely community rests atop a transplanted patch of famously red Rattanikiri soil. Together, without forest on this small reservation, this burial ground, they seem to be in a kind of incommunicable last stand. While the machines are finally stalled and silent, the animals seem to retain power. Their hidden wooden genitals were shaped roughly as weapons. Their mouths were carved open. They are hungry, now and for the next generation. And they might also be uttering fuck you.

# មនុស្ស កៅស៊ូ
# ដោយ ខ្វៃ សំណាង

# Rubber Man
## by Khvay Samnang

22 May - 12 July 2014



Khvay Samnang, *Rubber Man*, 2014, Digital C-Print, 120 x 180 cm

**About the Artist**
Khvay Samnang (b. 1982, Svay Rieng) engages with concepts of mediation, change and continuity. He offers new interpretations of history, longstanding cultural practices, and contentious current affairs. Khvay holds a BA in Painting (Royal University of Fine Arts, Phnom Penh, 2006). He is a founding member of the artist collective Stiev Selapak and the spaces Sa Sa Art Projects (2010) and SA SA BASSAC (2011). Select 2013 exhibition include *If the World Changed*, 4th Singapore Biennale, Singapore, *Everyday Life*, 4th Asian Art Biennial, Taiwan, *Phnom Penh: Rescue Archaeology*, ifa, Berlin and Stuttgart. Khvay is in residence at Künstlerhaus Bethanian, Berlin, 2014-2015.

**With Thanks**
The artist wishes to thank Mok Rotha, Roger Nelson, Chum Chanveasna, San Beouk, Oun Batham and Prum Bandiddh.